នាយកដ្ឋានជលផល

# បច្ចេកទេសផលិត

# កូនត្រីកន្ធរ




ស្ថានីយ៍ស្រាវជ្រាវ និងផលិតកូនត្រីពូជ បាទី

ស្រុកពាមរក៍ ខេត្តព្រៃវែង

គំរោងវារីវប្បកម្មប្រភេទត្រីក្នុងស្រុកនៃទន្លេមេគង្គ (AIMS)

គំរោងបង្កើនផលិតភាពកសិកម្ម ផ្នែកជលផល

(APIP , Fisheries Component) ២០០៣

# បច្ចេកទេសផលិតកូនត្រីកន្ធរ

(Seed Production *of Trichogaster pectoralis*)

**រៀបរៀងដោយ:**

លោក **ចិ៊វន់ ហេង** ប្រធានស្ថានីយ៍ស្រាវជ្រាវ និង ផលិតកូនត្រីពូជ បាទី

លោក **មាស វិចិត្រ** អនុប្រធានស្ថានីយ៍ស្រាវជ្រាវ និង ផលិតកូនត្រីពូជ បាទី

លោក **យូ ណាវុធ** មន្ត្រីបច្ចេកទេស នៃស្ថានីយ៍ស្រាវជ្រាវ និង ផលិតកូនត្រីពូជ បាទី

**កែសម្រួលដោយ:**

ក្រុមការងាររៀបចំចងក្រង និង បោះពុម្ពផ្សាយ

របស់នាយកដ្ឋានជលផល

ម.ព.ឯ.ក AIDOC

Code: 137-033

Date:

Donated by:

**ឧបត្ថម្ភដោយ:**

នាយកដ្ឋានជលផល/គម្រោងបង្កើនផលិតភាពកសិកម្ម (APIP)

# មាតិកា


| | |
|---|---|
| អារម្ភកថា | ១ |
| ១. សេចក្តីផ្តើម | ២ |
| ២. លក្ខណៈជីវសាស្ត្រ | ២ |
| ៣. ការជ្រើសរើសត្រីមេពូជ | ៥ |
| ៤. ស្រះថែបំប៉នត្រីមេពូជ | ៦ |
| ៥. ការថែបំប៉នត្រីមេពូជ | ៨ |
| ៦. ការបន្តពូជ | ៩ |
| ៧. វិធីសាស្ត្របង្កាត់ភ្ញាស់ | ៩ |
| ៨.ការថែបំប៉នកូនត្រីពូជ | ១៤ |
| ៩. ការផ្តល់ចំណី | ១៦ |
| ១០. បណ្ណាល័យសាស្ត្រ | ១៨ |

# អារម្ភកថា

ការចងក្រងឯកសារស្តីពី **បច្ចេកទេសផលិតកូនត្រីកន្ធរ** ត្រូវបានរៀបចំឡើង ដោយបានសិក្សាស្រាវជ្រាវ និងអនុវត្តជាក់ស្តែងផ្ទាល់នៅស្ថានីយ៍ស្រាវជ្រាវ និងផលិតកូនត្រីពូជ បាទី នៅឆ្នាំ ២០០២ ។ ឯកសារនេះ បានរៀបចំឡើងដើម្បីបំរើអោយការងារផ្សព្វផ្សាយ ដោយមានលក្ខណៈងាយយល់ ហើយកសិករអាចមានលទ្ធភាពអនុវត្តបាន។

លទ្ធផលនេះ ជាសមិទ្ធិផលមួយចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍វារីវប្បកម្មនូវប្រភេទពូជត្រីក្នុងស្រុក ដើម្បីបង្កើននូវម្ហូបត្រីជូនដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រនៅតាមមូលដ្ឋានឆ្ងាយពីដែនទឹកធម្មជាតិ ។ ដោយឡែកប្រជាកសិករ មានកាលានុវត្តភាពនឹងទទួលបាននូវនវានុវត្តន៍នៃបច្ចេកវិទ្យាថ្មី ដើម្បីអភិវឌ្ឍវារីវប្បកម្មផង និងដើម្បីបង្កើនជីវភាពរស់នៅផង អោយស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

កម្មវិធីស្រាវជ្រាវនូវប្រភេទត្រីក្នុងស្រុក ត្រូវបានការយកចិត្តទុកដាក់ និងជួយឧបត្ថម្ភគាំទ្រពីនាយកដ្ឋានជលផល មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្តព្រៃវែង គំរោងវារីវប្បកម្មត្រីក្នុងស្រុកនៃទន្លេមេគង្គ និង គំរោងបង្កើនផលិតភាពកសិកម្ម ។

យើងសង្ឃឹមថា អ្នកផលិតកូនត្រីពូជ អាចប្រើប្រាស់នូវឯកសារនេះ ដើម្បីផលិតកូនត្រីបានមួយប្រភេទទៀត បន្ថែមលើប្រភេទត្រីដែលបានផលិតកន្លងមក ដើម្បីរួមចំណែកអភិវឌ្ឍវារីវប្បកម្មកម្ពុជាអោយកាន់តែប្រសើរឡើង ។

## ១.សេចក្តីផ្តើម

ការផលិតកូនត្រីកន្ធរនេះ ស្ថានីយ៍បានអនុវត្តបច្ចេកទេសផលិតដោយពាក់កណ្តាលសិប្បនិម្មិត គឺយើងបានចាក់អរម៉ូន ហើយទុកអោយត្រីទំលាក់ពងដោយខ្លួនឯង តែយើងត្រូវប្រមូលពងត្រីមកភ្ញាស់ដោយរៀបចំឧបករណ៍ភ្ញាស់បានសមស្រប ។ ការផលិតកូនត្រីតាមបច្ចេកទេសខាងលើនេះ ទទួលបានលទ្ធផលខ្ពស់ជាងការផលិតកូនត្រីតាមបែបធម្មជាតិ ដោយអោយវាពងកូនផ្ទាល់នៅក្នុងស្រះត្រី ។

ត្រីកន្ធរជាប្រភេទត្រីមានតំលៃសេដ្ឋកិច្ចខ្ពស់ លើទីផ្សារក្នុងនិងក្រៅប្រទេស ។ ដូច្នេះការចិញ្ចឹមត្រីកន្ធរ អាចជួយបង្កើន នូវម្ហូបអាហារដល់គ្រួសារ និងទទួលបន្ថែមនូវថវិកាចំណូល ។

បច្ចុប្បន្ន កិច្ចអភិវឌ្ឍន៍វិស័យវារីវប្បកម្មជាលក្ខណ:គ្រួសារបាននិងកំពុងផ្សព្វផ្សាយយ៉ាងសកម្មដល់ប្រជាជនទូទៅ ជាពិសេសប្រជាកសិករក្រីក្រ នៅតាមតំបន់ដាច់ស្រយាលពីដែនទឹកធម្មជាតិ ។

## ២. លក្ខណ:ជីវសាស្ត្រ

### ២.១.ចំណាត់ថ្នាក់

- អំបូរ: Belontiidae
- ពូជ: *Trichogaster*

- ប្រភេទ: *pectoralis*
- ឈ្មោះវិទ្យាសាស្ត្រ: *Trichogaster pectoralis*
- ឈ្មោះធម្មតា: Snake skin gourami
- ឈ្មោះជាភាសាខ្មែរ : *ត្រីកន្ធរ*

**២.២.ប្រភព**

ត្រីកន្ធរជាប្រភេទត្រីទឹកសាប មានប្រភពនៅក្នុងប្រទេសកម្ពុជា វៀតណាម ថៃ ហើយបានរីកសាយនៅប្រទេសផ្សេងៗទៀតដូចជា ប្រទេសម៉ាឡេស៊ី សឹង្ហបូរី ឥណ្ឌូនេស៊ី ហ្វីលីពីន ប៉ាគីស្ថាន ឥណ្ឌា និងស្រីលង្កា (អាំផៃ ឆ្នាំ ១៩៩៧) ។

**២.៣.លក្ខណៈបន្សាំជីវិត**

ត្រីកន្ធរជាប្រភេទត្រីដែលចូលចិត្តរស់នៅក្នុងទឹកនឹង ដូចជា បឹង ត្រពាំង ថ្លុក ស្រែ និងប្រលាយ ដែលនៅទីនោះមានប្រភេទរុក្ខជាតិសំរាប់ធ្វើជាចំណីអាហារ ជាជំរកការពារខ្លួននិងជាកន្លែងសំរាប់ពងកូន ។ ត្រីកន្ធរជាប្រភេទត្រីដែលអាចរស់ក្នុងមជ្ឈដ្ឋានទឹកដែលមានកំរិត pH ទាប ។ ការលូតលាស់លឿននៅក្នុងទឹកដែលមានកំរិត pH សមស្រប ពី ៥.៦-៦ ហើយអាចធន់ទ្រាំក្នុងកំរិត pHពី ៤-៩ ។ ម៉្យាងទៀត វាអាចរស់នៅបានក្នុងទឹកដែលមានកំរិតអុកស៊ីសែនទាប ព្រោះវាមានប្រដាប់ដកដង្ហើមពិសេស ដែលអាចស្រូបយកអុកស៊ីសែនពី

បរិយាកាសបាន។ ត្រីកន្ធរអាចធន់ទ្រាំបានក្នុងកំរិតសីតុណ្ហភាពពី១១-៣៩$^{o}$C ហើយសីតុណ្ហភាពសមស្របពី ២៤-៣០$^{o}$C (Nguen Tuan and Huynh Ngai, ១៩៩០)។

## ២.៩.លក្ខណៈសំគាល់ត្រីមេ និង ឈ្មោល

ត្រីកន្ធរមេ និងឈ្មោលនៅក្នុងដំណាក់កាលពេញវ័យ មានលក្ខណៈខុសគ្នាមួយចំនួនដូចខាងក្រោម :

### ត្រីញី

- ព្រុយខ្នងខ្លីមិនអូសបន្លាយវែងដល់ព្រុយកន្ទុយទេ
- ឆ្នូតបញ្ឆិតពណ៌ខ្មៅពីខ្នងទៅពោះមិនសូវច្បាស់
- ឆ្នូតពណ៌ខ្មៅនៅតាមបណ្ដោយដងខ្លួនជាប់គ្នា
- ចំណុចពណ៌ខ្មៅនៅលើគំរបស្រកីច្បាស់

### ត្រីឈ្មោល

- ព្រុយខ្នងអូសបន្លាយវែងដល់គល់ព្រុយកន្ទុយ
- ឆ្នូតបញ្ឆិតពណ៌ខ្មៅមើលឃើញច្បាស់ពីខ្នងដល់ពោះ
- ឆ្នូតពណ៌ខ្មៅនៅតាមបណ្ដោយដងខ្លួនមិនជាប់គ្នា
- ចំណុចពណ៌ខ្មៅនៅលើគំរបស្រកីមិនសូវច្បាស់



ត្រីឈ្មោល



ត្រីញី

## ៣. ការជ្រើសរើសត្រីមេពូជ

ការជ្រើសរើសត្រីមេពូជគឺជាដំណាក់កាលមួយដ៏សំខាន់សំរាប់ធ្វើការបន្តពូជ ។ ការជ្រើសរើសត្រីមេពូជបានសមស្របធ្វើអោយកំលាំងបន្តពូជបានច្រើន។ លក្ខណៈនៃការការជ្រើសរើសត្រីមេពូជ មានដូចខាងក្រោម :

- ទំហំធំលើសពី ៨០ ក្រាម
- អាយុលើសពី ៧ ខែ
- ត្រីមេមានពោះប៉ោងហើយទន់ បើច្បូតលើពោះថ្នមៗឃើញមានគ្រាប់ពង ជ្រុះចេញមកខាងក្រៅរាយដាច់ពីគ្នា ហើយវាមានពណ៌លឿងស្រស់
- ចំពោះត្រីឈ្មោលបើច្បូតពោះវាថ្នមៗ យើងឃើញមានទឹកមេជីវិត "ស្ពែម" ហូរចេញមកក្រៅពណ៌ថ្លា